ក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ
*****
<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ
ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ទីក្រុងបាងកក-នន្ទបុរី

*****

ក្នុងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមក្នុងកិច្ចប្រជុំលើកទី២០របស់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និង កិច្ចប្រជុំលើកទី២៤របស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

**កិច្ចប្រជុំលើកទី២០របស់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន**

កិច្ចប្រជុំបានពិភាក្សាលើបញ្ហាសន្តិសុខប្រពៃណី និងមិនប្រពៃណីនានា ដែលជះឥទ្ធិពលទៅដល់ការវិវឌ្ឍថ្មីៗក្នុងបណ្តាផ្នែកចំណុះសហគមន៍នយោបាយ-សន្តិសុខអាស៊ាន និងវឌ្ឍនភាពនៃការអនុវត្តផែនការលំអិតរបស់សហគមន៍នយោបាយ-សន្តិសុខអាស៊ាន២០២៥។

ពាក់ព័ន្ធនឹងបញ្ហាប្រឈម និងផែនការនាពេលអនាគតត សម្រាប់ការអនុវត្តផែនការលំអិតរបស់សហគមន៍នយោបាយ-សន្តិសុខអាស៊ាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានសង្កត់ទៅលើផលប៉ះពាល់ធ្ងន់ធ្ងរនៃសន្តិសុខតាមប្រព័ន្ធអ៊ិនធឺរណែត និងភាពចាំបាច់ក្នុងកិច្ចប្រឹងប្រែងរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋឆ្លងដែន ជាពិសេស ការរត់ពន្ធគ្រឿងញៀនខុសច្បាប់។ **ឯកឧត្តម** បានជម្រាបជូនអង្គប្រជុំអំពីការរួមចំណែករបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់សកម្មភាពមីន (ARMAC) ក្នុងការលើកកម្ពស់ការយល់ដឹងអំពីគ្រោះថ្នាក់នៃគ្រាប់មីន និងសំណល់គ្រឿងផ្ទុះពីសង្គ្រាម នៅក្នុងតំបន់ និងពិភពលោក។ **ឯកឧត្តម** ក៏បានជម្រាបដល់អង្គប្រជុំអំពីលទ្ធផលនៃសិក្ខាសាលាតំបន់ស្តីពីការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងអាស៊ាន ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ កាលពីខែសីហា ឆ្នាំ២០១៩។

**កិច្ចប្រជុំលើកទី២៤របស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន**

កិច្ចប្រជុំបានពិភាក្សាលើតួនាទី និងប្រតិបត្តិការរបស់លេខាធិការដ្ឋានអាស៊ាន ការអនុវត្តផែនការសកម្មភាពនៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) និងវឌ្ឍនភាពនៃការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) ២០២៥។

នៅក្នុងបទអន្តរាគមន៍ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានអរគុណដល់រដ្ឋាភិបាលឥណ្ឌូនេស៊ីដែលបានប្តេជ្ញាចិត្តចំពោះអាស៊ាន សម្រាប់អគារនៃលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតាដែលទើបបានសម្ពោធនាពេលថ្មីៗកន្លងទៅនេះ។ ចំពោះ IAI **ឯកឧត្តម** បានអះអាងជាថ្មីអំពីសារសំខាន់នៃគំនិតផ្តួចផ្តើមនេះ ក្នុងការជំរុញសមាហរណកម្មនៅក្នុងតំបន់ និងបានលើកទឹកចិត្តឲ្យផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើការធ្វើឲ្យប្រសើរឡើងនូវកម្លាំងប្រកួតប្រជែងរបស់សហគ្រាសមីក្រូ តូច និងមធ្យម

ការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដើម្បីធ្វើឲ្យកាន់តែស៊ីជម្រៅសមាហរណកម្ម ឌីជីថល និងកម្មវិធីកសាងសមត្ថភាព។ ចំពោះសមាជិកភាពទីម័រឡេស្តេនៅក្នុងអាស៊ាន **ឯកឧត្តម** បាន បញ្ជាក់ថា កម្ពុជាគាំទ្រទីម័រឡេស្តេ ជាសមាជិកអាស៊ាន និងបានស្វាគមន៍នូវការវិវឌ្ឍជាវិជ្ជមាន តាមរយៈ បេសកកម្មស្វែងរកការពិត ដែលបានធ្វើឡើងកាលពីខែកញ្ញា ឆ្នាំ២០១៩។ **ឯកឧត្តម** ក៏បានលើកទឹកចិត្ត ឲ្យសរសេរស្តម្ភក្រុមប្រឹក្សាសេដ្ឋកិច្ច និងក្រុមប្រឹក្សាសង្គម-វប្បធម៌ រៀបចំបេសកកម្មស្វែងរកការពិតនៅ ទីម័រឡេស្តេឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅដើមឆ្នាំ២០២០។

នៅរសៀលថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានអញ្ជើញ ចូលរួមក្នុងកម្មវិធីអាហារពេលល្ងាចការងារសម្រាប់រដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលនៅក្នុងឱកាសនោះ បញ្ហាតំបន់ និងអន្តរជាតិ ដែលជាការយកចិត្តទុកដាក់រួម ត្រូវបានលើកយកមកពិភាក្សា។

នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រួមជាមួយរដ្ឋមន្ត្រី ការបរទេសអាស៊ានដទៃ បានចុះហត្ថលេខាលើលិខិតុបករណ៍នៃការចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និង កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (TAC) ដោយសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងដោយ ព្រះរាជាណាចក្របារាំង ៕

ថ្ងៃសៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩